ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ 204 PEAC.អក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការងារម៉ៅការផ្គត់ផ្គង់សម្ភារៈ និង ឈ្នួលពលកម្មសម្រាប់តំឡើង Primary Equipment និង Shunt Capacitor Bank 115 kV ដើម្បីបង្កើនតង់ស្យុងនៅអនុស្ថានីយ៍អគ្គិសនីសៀមរាប ក្នុងគោលដៅទទួលយកថាមពលបន្ថែមពីវ៉ារីអគ្គិសនី (ភាគខាងលិច)

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជានឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីការងារម៉ៅការផ្គត់ផ្គង់សម្ភារៈ និង ឈ្នួលពលកម្មសម្រាប់តំឡើង Primary Equipment និង Shunt Capacitor Bank 115 kV ដើម្បីបង្កើនតង់ស្យុងនៅអនុស្ថានីយ៍អគ្គិសនីសៀមរាប ក្នុងគោលដៅទទួលយកថាមពលបន្ថែមពីវ៉ារីអគ្គិសនី (ភាគខាងលិច)។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាសយដ្ឋាន៖ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ2016 តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទំនាក់ទំនងលេខ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង 14:00 ថ្ងៃទី 15 ខែ មីនា ឆ្នាំ 2016 ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាស័យដ្ឋានខាងលើ វេលាម៉ោង 15:00 ថ្ងៃទី 15 ខែមីនាឆ្នាំ 2016 ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃ បានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញមកទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី 12 ខែ កុម្ភៈ ឆ្នាំ 2016
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ឡឹម_អ៊ុង**

**ចម្លងជូន**
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ